ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រម
តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៦១៤ ·អ១·ក្រ១១
-ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខ ៩៤៩
ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣
-សំណុំរឿងស៊ើបសួរលេខ ៧០៥
ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះលេខ ១៧៩៣
ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ០២ និង ០០ នាទីរសៀល នៅសាលសវនាការទី២ ដោយមានសមាសភាព៖

ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ជាចៅក្រមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩៤៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] **សុខឌី** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត[redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួននៅបុរីសន្តិភាព២ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] **សុខតម្ភ** (រ) ម្តាយឈ្មោះ [redacted] **ចាន់លីន** (រ) នៅលីវ ជានីតិជន ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ០៣(បី)ឆ្នាំ ចេញពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ (ពីបទ:ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន) កម្រិតវប្បធម៌រៀនថ្នាក់ទី០៣។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៤២៦ "ធ"ដ.ឃ.ដ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣ នៅពន្ធនាគារាជធានីភ្នំពេញ(PJ) ។

២.ឈ្មោះ [redacted] **សុជារ៉ាត់** ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួននៅភូមិត្រពាំងសាលា សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] **ប៉ែន** (ស) ម្តាយឈ្មោះ [redacted] **សាមឿន** (រ) នៅលីវ ជានីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌រៀនថ្នាក់ទី០៤។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៤២៧ "ធ"ដ.ឃ.ដ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣ នៅពន្ធនាគារាជធានីភ្នំពេញ(PJ) ។

Scanned with CamScanner

ជាប់ចោទពីបទ: **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង៣០ម៉ែត្រ កែងច្រកចូលពន្ធនាគារ(PJ) ភូមិព្រៃធំ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៦១, ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ជនរងគ្រោះឈ្មោះ [redacted] **លីណា** មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ២៨X ផ្លូវលំ ភូមិ៦ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

លោកស្រី [redacted] មានអាសយដ្ឋានផ្ទះលេខ១៨១ ផ្លូវ១៥០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] សុខឌី និងឈ្មោះ [redacted] សុងារ៉ាត់ ។

លោកស្រី [redacted] មានអាសយដ្ឋានការិយាល័យអគារស៊ីអាយស៊ី(CIC) លេខ១២៦៥ ផ្លូវលំ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ មាស សុខឌី និងឈ្មោះ ប៉ែន សុងារ៉ាត់ ។

លោកស្រី [redacted] មានអាសយដ្ឋានការិយាល័យផ្ទះលេខ២២ និង២៤ លេខ២៨១ ផ្លូវលេខ២៨១ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] សុខឌី និងឈ្មោះ [redacted] សុងារ៉ាត់ ។

អត្ថហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល២២ និង៤៥នាទី មានករណី ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សា មួយកើតឡើងនៅចំណុចផ្លូវបេតុង៣០ម៉ែត្រ កែងច្រកចូលពន្ធនាគារ(PJ) ភូមិព្រៃធំ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ដោយមុនពេលកើតហេតុជនរងគ្រោះឈ្មោះ [redacted] លីណា បានជិះម៉ូតូស្កូបពីពណ៌ខ្មៅ ស្លាកលេខ ភ្នំពេញ 1IY-1578 ឧបមិត្តភក្តិឈ្មោះ [redacted] សៀកម៉េង ចេញពីផ្ទះនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីទៅទិញផ្លែឈើនៅផ្សារដើមគរ។លុះពេលជនរងគ្រោះបានធ្វើដំណើរមកដល់ចំណុចកើតហេតុខាងលើ ស្រាប់តែមានជនជាប់ចោទចំនួន០៣នាក់មានឈ្មោះ [redacted] សុងារ៉ាត់ , ឈ្មោះ [redacted] សុខឌី និងឈ្មោះ ឆៃ បានជិះម៉ូតូចំនួន០២គ្រឿង ម៉ាកស៊ីយស៊ីគីស្មាស់ ពណ៌សលាយខ្មៅ ស្លាកលេខ ភ្នំពេញ 1BC-8635 និងឈ្មោះ ម៉ូតូម៉ាកBEAT ពណ៌ខៀវ ពេលជនជាប់ចោទឈ្មោះ [redacted] សុងារ៉ាត់ បានជិះម៉ូតូមកអែបស្តាំដៃម៉ូតូជនរងគ្រោះរួចក៏បានធ្វើសកម្មភាពកៀរម៉ូតូរបស់ជនរងគ្រោះឱ្យចូលអែបកៀនផ្លូវ រួចជនជាប់ចោទឈ្មោះ ឆៃ បានបើកម៉ូតូម៉ាក ហុងដា BEAT ឧបជបសង្ស័យឈ្មោះ [redacted] សុខឌី មកឈប់នៅផ្លូវម្ខាង រួចស្ទុះរត់មកធ្វើសកម្មភាពព្រួតគ្នាទាត់ធាក់ទៅលើជនរងគ្រោះ បណ្តាលឱ្យជនរងគ្រោះរបួស ហើយជាំអ្នកខាងស្តាំ និងហើមខ្នងខាងឆ្វេង(របួសស្រាល)។នៅពេលជនជាប់ចោទបានធ្វើសកម្មភាពខាងលើក៏ឃើញថាជនរងគ្រោះដែលជាអ្នករស់នៅភូមិជាមួយគ្នាជនជាប់ចោទក៏រត់គេចខ្លួន។បន្ទាប់មកជនរងគ្រោះក៏បានដាក់ពាក្យបណ្តឹង លុះដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង១៤ និង៣០នាទី សមត្ថកិច្ចបានស្រាវជ្រាវ និងឃាត់ខ្លួនជនសង្ស័យចំនួន០២នាក់ ឈ្មោះ [redacted] សុខឌី និងឈ្មោះ [redacted] សុងារ៉ាត់ យកមកធ្វើការសាកសួរសមត្ថកិច្ចបានធ្វើគេសស្វែងរកសារធាតុញៀនជាលទ្ធផលវិជ្ជមាន លើឈ្មោះ [redacted] សុខឌី និងអវិជ្ជមានលើឈ្មោះ [redacted] សុងារ៉ាត់។

Scanned with CamScanner

-បានឃើញ របាយការណ៍សំយោគលេខ ០១៦/២៣ រ.ប.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលខណ្ឌដង្កោ និងស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៧១០ អ.យ.ត ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ១៧៣៧ អ.យ.ត ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ២២៥៦ ឈ.ដ.ដ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **សុខឌី** បានឆ្លើយថា៖ ខ្លួនសូមបដិសេធចំពោះការចោទប្រកាន់នេះ ព្រោះខ្លួនមិនបានប្រព្រឹត្តអ្វីចការចោទប្រកាន់នោះទេ។កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ខ្លួនបានជិះម៉ូតូBEAT ពណ៌ស ចេញពីផ្ទះស្ថិតនៅដំណាក់ត្រយឹង សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីទៅផឹកស្រាក្រឡុកនៅទល់មុខច្រកចូលពន្ធនាគារ(PJ) ស្ថិតនៅភូមិជ្រៃធំ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។រហូតដល់ម៉ោង២២ និង ៤៥នាទី ថ្ងៃខែឆ្នាំដដែល ស្រាប់តែឈ្មោះ [redacted] សុងាវ៉ាត ដែលត្រូវជាមីង បានធ្វើសកម្មភាពប្រតាយប្រតបគ្នាជាមួយឈ្មោះ សុខ លីណា បន្ទាប់ពីឃើញដូច្នេះ ខ្លួនក៏បានរត់ទៅជួយឈ្មោះ [redacted] សុងាវ៉ាត់ ដោយធ្វើសកម្មភាពទាត់ទៅលើឈ្មោះ [redacted] លីណា បណ្តាលឱ្យចំមុខចំនួន០១ដើង ទើបដឹងថាជាមនុស្សស្រីទើបខ្លួនឈប់វាយ ហើយជិះម៉ូតូសំដៅទៅផ្ទះ ឪពុយាយរបស់ខ្លួន និងបងស្រីដើម្បីមកកន្លែងកើតហេតុដើម្បីជួយឃាត់ខ្លួនឈ្មោះ [redacted] សុងាវ៉ាត់ កុំឱ្យឈ្លោះប្រកែកជាមួយគ្នាឈ្មោះ [redacted] លីណា បន្ទាប់មកពេលនោះមកឈ្មោះ [redacted] លីណា បានសំណូមពរឱ្យមីងខ្លួនសុំទោសគាត់ ប៉ុន្តែមីងរបស់ខ្លួនពុំបានសុំទោសគាត់ទេដែលធ្វើឱ្យគាត់ខឹងទៅប្តឹងសមត្ថកិច្ចតែម្តង។ខ្លួនពុំស្គាល់ឈ្មោះ [redacted] លីណា និងម្នាក់ទៀតនោះទេ។ប៉ុន្តែមានម្នាក់ដែលស្គាល់គ្នាជាមួយមីងរបស់ខ្លួន ហើយគាត់គឺជាប្រភេទមនុស្សស្រីស្រលាញ់ភេទដូចគ្នា ហើយគាត់ធ្លាប់មានបញ្ហាអ្វីជាមួយគ្នានោះ ខ្លួនមិនបានដឹងទេ។ខ្លួនទទួលស្គាល់ថាពិតជាបានវាយគេមែន ប៉ុន្តែចំពោះការចោទប្រកាន់ថាចង់ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយប្រើហិង្សានោះគឺមិនពិតទេ ខ្លួនចេះប្រើប្រាស់គ្រឿងញៀន។

-ជនជាប់ចោទឈ្មោះ [redacted] **សុងាវ៉ាត** បានឆ្លើយថា៖ខ្លួនពុំបានប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សាដោយប្រើអំពើហិង្សាដោយចោទប្រកាន់នោះទេ។កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែលដប់យប់ ខ្លួនបានជិះម៉ូតូមួយគ្រឿងម៉ាកស៊ុយស៊ីគីស្មាស់ ពណ៌សលាយខ្មៅ ផ្លាកលេខ 1CB-8635 តែម្នាក់ឯង ចេញពីផ្ទះជួលនៅភូមិត្រពាំងសាលា សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ ទៅមើលការប្រគុំតន្ត្រីនៅក្បែរវត្តធម្មត្រ័យ ស្ថិតនៅភូមិម្លៃបួន សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ពេលជិះម៉ូតូតាមផ្លូវបេតុង៣០ម៉ែត្រ ពីលិចទៅកើតដល់ណុចច្រកចូលពន្ធនាគារ(PJ) ក៏បានឃើញម៉ូតូ០១គ្រឿងម៉ាកស្កុបពី ពណ៌ខ្មៅ ឪពុគ្នាពីរនាក់ រួចបានមើលមុខខ្លួន ខ្លួនបានមើលមុខវិញហើយខ្លួនក៏បានឈប់ម៉ូតូ ស្រាប់តែអ្នកដែលបានប្តឹងខ្លួនឈ្មោះ [redacted] លីណា នេះបានជិះម៉ូតូទៅហួសហើយក៏បានបកក្រោយវិញ ហើយមកឈប់ក្បែរម៉ូតូខ្លួន ហើយពេលនោះខ្លួនក៏បានសួរទៅគាត់ថា ប្អូនឯងបកមកវិញ

ចង់យ៉ាងម៉េចជាមួយបង?ហើយក៏បានការប្រកែកពាក្យសម្តីគ្នា ក៏ខាងឈ្មោះ លីណា រុញច្រុងខ្លួនហើយខ្លួនក៏បានគ្រវាសដៃចេញហើយក៏បានប្រតាយប្រតបគ្នាទៅ។ពេលបំបែកគ្នាក៏ស្រាបតែឃើញក្បួយខ្លួនឈ្មោះ [redacted] សុខឌី នៅកន្លែងកើតហេតុដែរ ។ក្រោយមកខាងគេក៏ហៅបងប្អូនគេមក ហើយខ្លួនក៏ហៅបងប្អូនខ្លួនមកដោះស្រាយគ្នា ហើយក៏បានបែកគ្នាទៅផ្ទះរៀងខ្លួន។ស្រាប់តែនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ក៏មានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនមិនចេះប្រើប្រាស់ថ្នាំញៀន។

-តាមអំណានចម្លើយឈ្មោះ [redacted] លីណា បានឆ្លើយតំណាក់កាលសមត្ថកិច្ចថា ៖កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០២៣ វេលាម៉ោងប្រហែល២២ និង៤៥នាទី ខ្លួនបានជិះម៉ូតូ០១គ្រឿងម៉ាកស្កូបពីពណ៌ខ្មៅ ពាក់ផ្លាកលេខភ្នំពេញ 1IY-1578 មានលេខតួ និងលេខម៉ាស៊ីន 5170538 ឧបមិត្តភក្តិឈ្មោះ ថា សៀកម៉ែង ចេញពីផ្ទះស្ថិតនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីទៅទិញផ្លែឈើនៅផ្សារដើមគរ។ ពេលខ្លួន និងមិត្តភក្តិជិះម៉ូតូឧបគ្នាតាមផ្លូវបេតុង៣០ម៉ែត្រ ពីលិចទៅកើតដល់ចំណុចកែងច្រកចូលពន្ធនាគារ(PJ) ស្ថិតនៅភូមិជ្រៃធំ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ស្រាប់តែមានមនុស្សស្រីម្នាក់តែងខ្លួនជាប្រុសមិនស្គាល់ឈ្មោះជិះម៉ូតូ០១គ្រឿងម៉ាកស៊ុយស៊ូគីស្មាស់ ពណ៌សលាយខ្មៅ មិនចាំផ្លាកលេខ បានកៀរម៉ូតូខ្លួនឲ្យអែបកៀន។ពេលនោះឈ្មោះ [redacted] សៀកម៉ែង បានសួរម្នាក់ស្រីនោះថា ហេតុអ្វីបានជាបងជិះម៉ូតូតាមពីក្រោយខ្ញុំចឹង ស្រាប់តែមានមនុស្សប្រុស០២នាក់ ជិះម៉ូតូម៉ាក BEAT ពណ៌ខៀវ មិនចាំផ្លាកលេខ មកឈប់នៅម្ខាងផ្លូវ រួចស្ទុះរត់មករកពួកខ្លួន និងទាត់ធាក់មកលើខ្លួន ក្នុងគោលបំណងប្លន់យកម៉ូតូ តែចៃសដន្យបក្ខពួកម្នាក់បានស្គាល់ឈ្មោះ [redacted] សៀកម៉ែង ទើបពួកគេ បានឈប់ធ្វើសកម្មភាពហើយនាំគ្នាបើកម៉ូតូរត់គេចខ្លួនបាត់ រួចក៏បានមករាយការណ៍ប្រាប់សមត្ថកិច្ច និងដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលព្រៃតែម្តង។

-តាមអំណានចម្លើយឈ្មោះ [redacted] **សៀកម៉ែង** បានឆ្លើយតំណាក់កាលសមត្ថកិច្ចថា ៖កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០២៣ វេលាម៉ោងប្រហែល២២ និង៤៥នាទី ខ្លួនបានជិះម៉ូតូ០១គ្រឿងម៉ាកស្កូបពីពណ៌ខ្មៅ ពាក់ផ្លាកលេខភ្នំពេញ 1IY-1578 មានលេខតួ និងលេខម៉ាស៊ីន 5170538 ជាមួយឈ្មោះ [redacted] លីណា ចេញពីផ្ទះនៅបុរីសន្តិភាព២ ស្ថិតនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីទៅទិញផ្លែឈើនៅផ្សារដើមគរ។ពេលខ្លួន និងមិត្តភក្តិជិះម៉ូតូឧបគ្នាតាមផ្លូវបេតុង៣០ម៉ែត្រ ពីលិចទៅកើត។ ដល់ចំណុចកែងច្រកចូលពន្ធនាគារ(PJ) ស្ថិតនៅភូមិជ្រៃធំ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ស្រាប់តែមានមនុស្ស០៣នាក់ ឈ្មោះ [redacted] សុងារ៉ាត់ ,ឈ្មោះ [redacted] សុខឌី ,ឈ្មោះ ឆៃ បានជិះម៉ូតូ០២គ្រឿងទី១ម៉ាកស៊ុយស៊ូគីស្មាស់ ពណ៌សលាយខ្មៅ ផ្លាកលេខ ភ្នំពេញ 1CB-8635 ម៉ូតូម៉ាកហុងដា BEAT ពណ៌ខៀវ មិនចាំផ្លាកលេខ ។ពេលឈ្មោះ [redacted] សុងារ៉ាត់ បានបើកម៉ូតូម៉ាក ស៊ុយស៊ូគីស្មាស់ ម្នាក់ឯង មកខាងស្តាំដៃ រួចធ្វើសកម្មភាពកៀរម៉ូតូរបស់ពួកខ្លួនឲ្យចូលអែបកៀនផ្លូវហើយឈ្មោះ ឆៃ បានបើកម៉ូតូម៉ាក់ហុងដា BEAT ឧបឈ្មោះ [redacted] សុខឌី មកឈប់នៅម្ខាងផ្លូវ រួចចុះរត់មកធ្វើសកម្មភាពព្រួតគ្នាទាត់ធាក់ទៅលើពួកខ្លួនបណ្តាលឲ្យឈ្មោះ [redacted] លីណា រងរបួសហើមជាំក្រោមភ្នែកខាងស្តាំ និងខ្នងខាងឆ្វេង(របួសស្រាល)។ពេលកំពុងធ្វើសកម្មភាពនោះ ខ្លួនក៏បានស្គាល់ឈ្មោះ [redacted] សុងារ៉ាត់ ដោយរស់នៅក្នុងភូមិជាមួយគ្នា នៅ

Scanned with CamScanner

ពេលធ្វើសកម្មភាព ហើយពួកគេក៏បានទាំគ្នាជិះម៉ូតូរត់គេចខ្លួនបាត់។ បន្ទាប់មកខ្លួនក៏បានមកវាយការណ៍ប្រាប់សមត្ថកិច្ច និងដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលព្រៃស ទៅលើជនជាប់ចោទចំនួន០២នាក់ រួមនិងវត្ថុតាង ម៉ូតូ០១ គ្រឿង ម៉ាកស៊ុយស៊ូគីស្មាស ពណ៌សលាយខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1CB-8635 មានលេខតួBE4EM-131345 និងលេខម៉ាស៊ីន E480-131345 ហើយខ្លួនក៏បានមកធ្វើការបំភ្លឺជូនសមត្ថកិច្ចនៅអធិការដ្ឋាននគរបាលខណ្ឌដង្កោតែម្តង។

សេចក្តីសន្និដ្ឋានបឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការសាកសួរដេញដោយរួចមកឃើញថា ជនជាប់ចោទបានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សានោះទេ ដែលចឆ្លើយនេះមិនមានភាពស៊ីសង្វាក់គ្នាទៅនឹងរបាយការណ៍របស់សមត្ថកិច្ច ដែលអាចបញ្ជាក់បានថាជនជាប់ចោទពិតជាបានប្រព្រឹត្តអ្វីចការចោទប្រាកដមែន ហេតុនេះតំណាងអយ្យការនៅតែតំកល់ការចោទប្រកាន់អ្វីចក្នុងដីកាសន្និដ្ឋានស្តាពរលេខ ១៧៣៧ អ.យ.ត ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ ដដែល និងស្នើសុំទៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

- លោកស្រីមេធាវី [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុងារ៉ាត់ ,ឈ្មោះ [redacted] សុខឌី បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនមិនបានប្រព្រឹត្តអ្វីចការចោទប្រកាន់នោះទេ គ្រាន់តែបានប្រើអំពើហិង្សាវាយគ្នាប្រតាយប្រតបទៅវិញទៅមកតែប៉ុណ្ណោះ ហេតុអ្វីចនេះស្នើសុំសូមឲ្យតុលាការកែប្រែបទចោទពីបទ៖ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មកជាបទ៖ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនវិញ ហើយសុំឲ្យតុលាការផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនផង។

សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សុងារ៉ាត់ បាននិយាយសំដីចុងក្រោយបង្អស់ថា ខ្លួនសំណូមពរដល់តុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ខ្លួនដឹងពីកំហុសហើយ។

-ជនជាប់ចោទឈ្មោះ [redacted] សុខឌី បាននិយាយសំដីចុងក្រោយបង្អស់ថា ខ្លួនសំណូមពរដល់តុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ខ្លួនដឹងពីកំហុសហើយ។

តុលាការ

-ក្រោយពីបានស្តាប់ចឆ្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

Scanned with CamScanner

សំអាងហេតុ

១.តុលាការបានទទួលជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៩៤៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយដីកាបញ្ជូនរឿងមកជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ស្របតាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល២២ និង៤៥នាទី នៅចំណុចផ្លូវបេតុង៣០ម៉ែត្រ កែងច្រកចូលពន្ធនាគារ(PJ) ភូមិព្រៃធំ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ឈ្មោះ [redacted] សុងារ៉ាត់ ,ឈ្មោះ [redacted] សុខឌី បានប្រព្រឹត្តអំពើហិង្សាដោយចេតនា ទៅលើឈ្មោះ [redacted] លីណា អាទស្រី ពិតមែន។អំពើរបស់ជនជាប់ចោទទាំងពីរនាក់ មិនមែនជាអំពើ ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស ដែលចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះនោះទេ។

៣.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុងារ៉ាត** បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួនបានជិះម៉ូតូតែម្នាក់ឯងទៅមើលការប្រគុំតន្ត្រីនៅក្បែរវត្តធម្មត្រ័យ។ពេលខ្លួនជិះម៉ូតូតាមផ្លូវបេតុង៣០ម៉ែត្រ ដល់ចំណុចច្រកពន្ធនាគារPJ មានមនុស្សពីរនាក់ជិះម៉ូតូឌុបគ្នា បានមើលមុខខ្លួន ខ្លួនបានមើលមុខវិញហើយបានឈប់ម៉ូតូ មនុស្សពីរនាក់នោះបានជិះហួស ហើយបានជិះបកមករកខ្លួនវិញ ឈប់ម៉ូតូនៅក្បែរខ្លួន ហើយខ្លួនបានសួរថាប្អូនចង់យ៉ាងម៉េចជាមួយខ្លួន ? ហើយបានប្រកែកគ្នាជាមួយឈ្មោះ [redacted] លីណា ហើយឈ្មោះ [redacted] លីណា បានរុញច្រំងខ្លួន ខ្លួនបានក្រវាសដៃចេញ និងបានប្រតាយប្រតបគ្នា។ នៅពេលបែកគ្នា ឃើញឈ្មោះ [redacted] សុខឌី ជាមួយក្មួយខ្លួនមកដល់កន្លែងកើតហេតុខាងលើឈ្មោះ [redacted] លីណា ក៏បានតេទៅហៅបងប្អូនមក និងបានបែកគ្នាទៅផ្ទះរៀងខ្លួន។

៤.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុខឌី** បានឆ្លើយថា៖ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង១០ និង៤៥នាទី ខ្លួនបានធីកស៊ីទៅទល់មុខច្រកចូលពន្ធនាគារPJ ក្នុងសង្កាត់ព្រៃ ខណ្ឌដង្កោ បានឃើញឈ្មោះ [redacted] សុងារ៉ាត់ ជាមីងរបស់ខ្លួន វាយប្រតាយប្រតប់គ្នា ជាមួយអ្នកផ្សេង ខ្លួនបានរត់ទៅជួយ ហើយខ្លួនបានទាត់ទៅលើមនុស្សស្រីឈ្មោះ [redacted] លីណា មួយជើងចំមុខ ហើយទើបដឹងថាជាមនុស្សស្រី ខ្លួនក៏ឈប់វាយ និងបានជិះម៉ូតូទៅឌុបយាយ និងបងស្រីរបស់ខ្លួនមកជួយឃាត់កុំឲ្យឈ្លោះគ្នា។នៅពេលនោះឈ្មោះ [redacted] លីណា បានឲ្យឈ្មោះ [redacted] សុងារ៉ាត់ សុំទោស តែឈ្មោះ [redacted] សុងារ៉ាត់ មិនសុំទោសទេ ទើបមានការប្តឹងទៅសមត្ថកិច្ច។ខ្លួនពុំស្គាល់ឈ្មោះ [redacted] លីណា និងមនុស្សម្នាក់ទៀតជិះម៉ូតូជាមួយឈ្មោះ [redacted] លីណា នោះទេ។ ឈ្មោះ [redacted] សុងារ៉ាត ជាមនុស្សស្រីស្រលាញ់ស្រីអូចគ្នា។ខ្លួនមិនបានប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសអ្វីចការចោទប្រកាន់ឡើយ។

៥.ចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុងារ៉ាត់** និងចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុខឌី** ថាខ្លួនមិនបានប្រព្រឹត្តអំពើ ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស អ្វីចការចោទប្រកាន់នោះទេអាចឲ្យតុលាការជឿបាន ពីព្រោះគ្មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទថាបានប្រព្រឹត្តអំពើ ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស នោះឡើយ។អំពើរបស់ជនជាប់ចោទទាំងពីរនាក់បានប្រព្រឹត្តកាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ម៉ោង២២ និង៤៥នាទី នៅចំណុចផ្លូវ៣០ម៉ែត្រ កែងផ្លូវចូលពន្ធនាគារPJ នោះមានធាតុផ្សំបទល្មើសត្រឹមត្រូវតែបទ ហិង្សាដោយចេតនា តែប៉ុណ្ណោះ ។

៦.តាមអំណានចម្លើយឈ្មោះ [redacted] **លីណា** និងឈ្មោះ [redacted] **សៀកម៉េង** បានឆ្លើយតំណាក់កាលសមត្ថកិច្ចថា ៖ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល២២ និង៤៥នាទី ខ្លួនបានជិះម៉ូតូជាមួយគ្នាគោលបំណងទៅទិញផ្លែឈើនៅផ្សារដើមគរ ដល់ចំណុចផ្លូវបេតុង៣០ម៉ែត្រកែងច្រកចូលពន្ធនាគាររាជធានីភ្នំពេញ(PJ) មានមនុស្ស

Scanned with CamScanner

ស្រីម្នាក់តែងខ្លួនជាប្រុសមិនស្គាល់ឈ្មោះជិះម៉ូតូមកគៀរម៉ូតូខ្លួនឲ្យអែមកៀន។ ឈ្មោះ [redacted] សៀកម៉ែង បានសួរថា ហេតុអ្វីបានជិះម៉ូតូតាមក្រោយខ្លួនចឹង? ហើយឃើញមានមនុស្សប្រុសពីរនាក់ ជិះម៉ូតូម៉ាកហុងដាBEATមកឈប់ម្ខាងផ្លូវ បានស្ទុះមកទាត់ធាក់ខ្លួន បណ្តាលឲ្យឈ្មោះ [redacted] លីណា ហើមជាំភ្នែកស្តាំ និងហើមខ្នងខាងឆ្វេងរបួសស្រាល។

៧.តាមអង្គហេតុ និងតាមចម្លើយជនជាប់ចោទ,ចម្លើយឈ្មោះ [redacted] លីណា,ចម្លើយឈ្មោះ [redacted] សៀកម៉ែង តុលាការយល់ឃើញថា អង្គហេតុកើតឡើងកាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ម៉ោង ២២ និង៤៥នាទី នៅផ្លូវបេតុង៣០ ម៉ែត្រ កែងច្រកចូលពន្ធនាគារPJ ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ[redacted] សុងារ៉ាត និងជនជាប់ចោទឈ្មោះ [redacted] សុខឌី គ្មានធាតុផ្សំនៃបទល្មើស ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស ដូចការចោទប្រកាន់បញ្ជូនមកជំនុំជម្រះរបស់ចៅក្រមស៊ើបសួរនោះទេ គប្បីតុលាការសម្រេចកែប្រែបទចោទឲ្យបានត្រឹមត្រូវ។

៨.តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ(ដែនកំណត់នៃការប្តឹងទៅតុលាការចំពោះអង្គហេតុ)បានចែងថា តុលាការបានសម្រេចក្តី បានតែទៅលើអំពើទាំងឡាយណាដែលបានបង្ហាញនៅក្នុង សាលដីកាបញ្ជូន ដីកាបញ្ជូន ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម។សំណុំរឿងព្រហ្មទណ្ឌលេខ ៩៤៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ តុលាការទទួលជំនុំជម្រះដោយដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ។

៩.ជនជាប់ចោទឈ្មោះ [redacted] **សុខឌី** បានឆ្លើយសារភាពថា ខ្លួនបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនពិតមែន ដែលស្របទៅនឹងកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀនរបស់សមត្ថកិច្ចនគរបាល ដូចនេះការចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] **សុខឌី** ពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន គឺត្រឹមត្រូវតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១០.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការសាកសួរដេញដោយរួចមកឃើញថាជនជាប់ចោទបានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សានោះទេ ដែលចម្លើយនេះមិនមានភាពស៊ីសង្វាក់គ្នាទៅនឹងរបាយការណ៍របស់សមត្ថកិច្ច ដែលអាចបញ្ជាក់បានថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រាកដមែន។ ហេតុនេះតំណាងអយ្យការនៅតែតំកល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្តាពរលេខ ១៧៣៧ អ.យ.ត ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ ដដែល ស្នើសុំចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ ការសន្និដ្ឋានរបស់តំណាងអយ្យការដែលរក្សាការចោទប្រកាន់លើជនជាប់ចោទពីបទ ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស គឺពុំត្រឹមត្រូវទេ ដោយហេតុថាអំពើរបស់ជនជាប់ចោទគ្មានចេតនា ប៉ុនប៉ងយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះនោះទេ គឺចេតនារបស់ជនជាប់ចោទត្រឹមតែជាអំពើហិង្សាទៅលើជនរងគ្រោះតែប៉ុណ្ណោះ គប្បីតុលាការពិចារណាតាមអង្គហេតុ និងធាតុផ្សំបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្ត ។

១១.មេធាវី [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុងារ៉ាត់ ,ឈ្មោះ [redacted] សុខឌី បានធ្វើសេចក្តីសន្និដ្ឋានថា ក្ងតក្តីខ្លួនមិនបានប្រព្រឹត្ត អំពើប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស ដូចការចោទប្រកាន់នោះទេ គ្រាន់តែបានប្រើអំពើហិង្សាវាយគ្នាប្រតាយប្រតបទៅវិញទៅមកតែប៉ុណ្ណោះ។ ហេតុដូចនេះស្នើសុំសូមឲ្យតុលាការកែប្រែបទចោទពីបទ៖ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សា មកជាបទ៖ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ សេចក្តីសន្និដ្ឋានរបស់

Scanned with CamScanner

មេធាវីការពារជនជាប់ចោទ និងការស្នើសុំឱ្យតុលាការកែប្រែបទចោទពីបទ៖បទប៉ុប៉ងលួចមានស្ថានទម្ងន់ទោស មកជាបទហិង្សាដោយចេតនា គឺត្រឹមត្រូវ តប្បីតុលាការទទួលយកមកពិចារណា។

១២.អំពើរបស់ជនជាប់ចោទបណ្តាលអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម ដែលច្បាប់បានបញ្ញត្តិទុកជាបទល្មើសព្រហ្មទណ្ឌ ដែលតម្រូវឱ្យផ្តន្ទាទោស។

១៣.ជនជាប់ចោទឈ្មោះ [redacted] **សុខឌី** និងឈ្មោះ [redacted] **សុដាវ៉ាត់** ជានីតិជន និងជាជនដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ស្របតាមមាត្រា ៣៨ នៃក្រមព្រហ្មណ្ឌ តុលាការត្រូវផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

១៤.គ្មានភស្តុតាងនឹងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សុដាវ៉ាត់** ភេទស្រី អាយុ៣៧ឆ្នាំ និងឈ្មោះ [redacted] **សុខឌី** ភេទប្រុស អាយុ២៣ឆ្នាំ (អត្តសញ្ញាណដូចខាងលើ) ពីបទ: **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង៣០ម៉ែត្រ កែងច្រកចូលពន្ធនាគារ(PJ) ភូមិព្រៃធំ សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៦១ ,មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ នោះទេ។

១៥. មានភស្តុតាងនឹងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សុខឌី** ភេទប្រុស អាយុ២៣ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] **សុដាវ៉ាត់** ភេទស្រី អាយុ៣៧ឆ្នាំ (អត្តសញ្ញាណដូចខាងលើ) ពីបទ: **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង៣០ម៉ែត្រ កែងច្រកចូលពន្ធនាគារ(PJ) ភូមិព្រៃធំ សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ និងជនជាប់ចោទឈ្មោះ [redacted] **សុខឌី** ភេទប្រុស អាយុ២៣ឆ្នាំ មានពិរុទ្ធភាពពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន តាមមាត្រា ៣៥០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការប្រកាសផ្តន្ទាទោសតាមច្បាប់បញ្ញត្តិ ។

១៦.ជនជាប់ចោទឈ្មោះ [redacted] **សុដាវ៉ាត់** ,ឈ្មោះ [redacted] **សុខឌី** បានឱ្យឈប់ដំចុងក្រោយសុំឱ្យតុលាការបន្ថយបន្ថយទោសឱ្យខ្លួន សន្យាកែប្រែខ្លួន ឈប់ប្រព្រឹត្តបទល្មើសទៀតហើយ។ តុលាការអាចទទួលយកមកពិចារណាក្នុងការប្រកាសទោសក្រោមអតិបរមានៃទោសដែលច្បាប់កំណត់។

១៧.ជនរងគ្រោះឈ្មោះ [redacted] **លីណា** ពុំបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណងរដ្ឋប្បវេណីនោះទេ តុលាការមិនពិចារណា និងសម្រេចអំពីសំណងឡើយ។

<u>ហេតុដុំផ្លេះសម្រេច</u>

I.កែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted] **សុខឌី** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] **សុដាវ៉ាត់** ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ (អត្តសញ្ញាណដូចខាងលើ) ពីបទ៖**ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សា** តាមមាត្រា ៣៦១, ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ មកជាបទ៖ **ហិង្សាដោយចេតនា** តាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

II.ផ្តន្ទាទោសជនជាប់ចោទ៖

១.ជនជាប់ចោទឈ្មោះ [redacted] **សុជាវ៉ាត់** ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ០១(មួយ)ឆ្នាំ ។

ពីបទ: **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង៣០ម៉ែត្រ កែងច្រកចូលពន្ធនាគារ(PJ) ភូមិព្រៃធំ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

២.ឈ្មោះ [redacted] **សុខឌី** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ០១(មួយ)ឆ្នាំ ។

ពីបទ៖ **ហិង្សាដោយចេតនា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង៣០ម៉ែត្រ កែងច្រកចូលពន្ធនាគារ(PJ) ភូមិព្រៃធំ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

III.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២១ ខែសីហា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សុជាវ៉ាត់** ,ឈ្មោះ [redacted] **សុខឌី** ។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ	ចៅក្រមប្រឹក្សា	ចៅក្រមប្រឹក្សា	ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខា និង ត្រា ៖	ហត្ថលេខា និង ត្រា ៖	ហត្ថលេខា និង ត្រា ៖	ហត្ថលេខា និង ត្រា ៖

[redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃចន្ទ ៥កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣
ក្រឡាបញ្ជី

[redacted]

Scanned with CamScanner